**អនុក្រឹត្យ លេខ ៧២ អនក្រ.បក**

**ស្តីពីការបង្កើតក្រុមហ៊ុនចំការកៅស៊ូ ពាមជាំង**

---------------

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្សទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត ០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូ អោយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**សំរេច**

**មាត្រា១.-** ត្រូវបានបង្កើតក្រុមហ៊ុនចំការកៅស៊ូពាមជាំង មានថ្នាក់ស្មើនាយកដ្ឋាន ស្ថិតនៅក្រោមអាណាព្យាបាលរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ដោយកាត់យកភូមិសាស្ត្រ មូលដ្ឋានចំការកៅស៊ូពាមជាំង នៃក្រុមហ៊ុនចំការកៅស៊ូជប់ ទៅតាមផែនទីភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

**មាត្រា២.-** ក្រុមហ៊ុនចំការស៊ូពាមជាំង ជាអង្គភាពសាធារណៈ ប្រភេទក្រុមហ៊ុនរដ្ឋ ត្រូវបានអនុវត្តតាមបទបញ្ញត្តិ នៃលក្ខន្តិកៈទូទៅរបស់សហគ្រាសសាធារណៈ ។

**មាត្រា ៣.-** ក្រុមហ៊ុនចំការកៅស៊ូពាមជាំង មានមុខងារ និងភារៈកិច្ចដូចខាងក្រោម :

-កសាងផែនការកម្មវិធីអភិវឌ្ឍន៍ដំណាំកៅស៊ូ ដោយប្រើប្រាស់ដំណាំកៅស៊ូដែលមានស្រាប់ និងដាំដុះថ្មី ។

-ដឹកនាំនិងសំរេចរាល់សកម្មភាពផលិតកម្មអាជីវកម្ម ដំណាំកៅស៊ូរបស់ក្រុមហ៊ុន សំដៅជំរុញអភិវឌ្ឍន៍ បង្កើនទិន្នផលទាំងបរិមាណ និងគុណភាពកៅស៊ូ ។

-ចូលរួមសកម្មភាពក្នុងការជំរុញផ្នែកវិទ្យាសាស្ត្រ បច្ចេកទេសដំណាំកៅស៊ូ ។

-ដឹកនាំ និង គ្រប់គ្រងខ្សែសង្វាក់គ្រឿងចក្រផលិតកម្មជឿនលឿន និងរោងចក្រកែច្នៃជ័រកៅស៊ូ ដើម្បីធានាគុណភាព និងទិន្នផលខ្ពស់ ។

- កសាងប្រព័ន្ធបៀវត្សអោយបានសមស្របតាមសភាពការណ៍សេដ្ឋកិច្ចទីផ្សារ លើកកំពស់ជីវភាពរស់នៅ វប្បធម៌ អប់រំ ថែបំប៉នសុខភាព សន្តិសុខ ជូនមន្ត្រីបុគ្គលិក កម្មករ បំរើការងារក្នុងក្រុមហ៊ុន និងបន្ទុកគ្រួសាររបស់គេអោយមានស្មេរភាពត្រឹមត្រូវល្អ ។

**មាត្រា ៤.-** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានចំការកៅស៊ូ ត្រូវកំណត់ និងបែងចែកចលនៈ អចលនៈទ្រព្យ និងកំលាំងពលកម្ម ដែលពាក់ព័ន្ធ ចេញពីក្រុមហ៊ុនចំការកៅស៊ូជប់ ប្រគល់ជូនក្រុមហ៊ុនចំការកៅស៊ូពាមជាំង ដើម្បីដំណើរការផលិតកម្ម និងអាជីវកម្ម ។

**មាត្រា៥.-** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពចំណុះក្រុមហ៊ុននេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៦.-** ក្រុមហ៊ុនចំការស៊ូពាមជាំង ដឹកនាំដោយនាយកក្រុមហ៊ុនមួយរូប និងនាយករងមួយចំនួនជាជំនួយការ ។

**មាត្រា ៧.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ុង ហួត ហ៊ុន សែន**

--------------

**អនុក្រឹត្យ លេខ: ២១០ អនក្រ.តត**

**ស្តីពីការផ្ទេរភារកិច្ចនាយនគរបាលជាតិ**

----------------

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ